ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០២០ សហវ.

# សារាចរណែនាំ
## ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា
## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០១២

យោងសារាចរណែនាំលេខ ០៨ សរណន ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ។

យោងប្រកាសលេខ ៧៤០ សហវ.ហម.ប្រក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១០ ស្តីពីការបង្កើតថវិកាផ្នែកសម្រាប់ក្រុង ស្រុក ខណ្ឌ ដែលមានរចនាសម្ព័ន្ធការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១២ ដូចខាងក្រោម ៖

## I. ការរៀបចំចំណូលថវិកា

1. ចំណូលចរន្តថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានគិតគូរលើមូលដ្ឋានប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដែលបានកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គម្រោងចំណូលថវិកានេះត្រូវបានរៀបចំដូចតទៅ ៖

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ៖
  + លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  + ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  + ប៉ាន់ស្មានលើការរីកចម្រើនសេដ្ឋកិច្ចនៅពេលខាងមុខ
  + ការប្រែប្រួលដែលអាចកើតមានឡើងដោយអត្រា និងចំនួនមូលដ្ឋានប្រមូលពន្ធ
  + ចំណូលដែលសង្ឃឹមថា បានមកពីការបង្កើតពន្ធថ្មី
  + ដូចជាពន្ធលើអចលនទ្រព្យ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងក្នុងមាតិកាថវិកាអនុគណនី ៧០៧១ ពន្ធលើអចលនទ្រព្យរូបវន្តបុគ្គល និងអនុគណនី៧០៧២ ពន្ធលើអចលនទ្រព្យនីតិបុគ្គល។
- ទន្ទឹមនឹងនេះ ចំណូលមិនមែនសារពើពន្ធត្រូវបានគិតគូរទៅតាមកិច្ចការដែលនាំឲ្យមានផលទុនដូចជា កិច្ចសន្យាជួល សេវាកម្ម និងកែលំអអគារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋព្រមទាំងប្រមូលបំណុលដែលត្រូវទារជាដើម ។ ចំណូលទាំងអស់នេះត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិសម្រេចបាននៃឆ្នាំកន្លងមក និងការរីកចម្រើននៃសេដ្ឋកិច្ច ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ចំពោះនីតិវិធី គឺអភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវអញ្ជើញមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាខាពន្ធដារ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញដែលពាក់ព័ន្ធក្នុងការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ។

2. ចំណូលផ្ទៃក្នុងជាមូលធនរបស់ថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងករណីដែលមាន គឺត្រូវយកចិត្តទុកដាក់បញ្ចូលទៅក្នុងគម្រោងចំណូលនៃជំពូក១៣ ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលនូវចំណូលពីជំនួយមនុស្សធម៌ និងជំនួយពីបរទេសដែលសប្បុរសជនអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានទៅទំនាក់ទំនងផ្តល់ហិរញ្ញប្បទានផ្ទាល់ជាមួយរាជធានី ខេត្ត រួចហើយ ។ សម្រាប់ថវិការាជធានី ខេត្ត ដើម្បីមកចូលរួមពិភាក្សាគិតគូររៀបចំជាគម្រោងចំណូលទៅតាមជំពូក គណនី អនុគណនី នៃតារាងឧបសម្ព័ន្ធទី ១ ដែលជូនភ្ជាប់មកជាមួយនេះ ។

## II. ការរៀបចំចំណាយថវិកា

3. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំនូវគម្រោងចំណាយទៅតាមជំពូក គណនី អនុគណនី សម្រាប់រាល់សកម្មភាពសេវាទាំងអស់ដោយកាត់បន្ថយមុខចំណាយណាដែលពុំចាំបាច់ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។ របៀបគិតគូរនូវតម្រូវការនានា គឺជាការកំណត់នូវមុខចំណាយនីមួយៗឲ្យច្បាស់លាស់ និងដោយផ្អែកលើកត្តានានាដែលទាក់ទងផ្ទាល់ទៅនឹងមុខចំណាយនោះដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានបរិមាណ តំលៃ សម្ភារៈ ឬសេវា.....។ ចំពោះសម្ភារៈបរិក្ខាដែលប្រើប្រាស់ជាប្រចាំត្រូវគិតគូរដោយផ្អែកតាមតួលេខស្ថិតិគណនេយ្យថវិកាជាមធ្យមភាគនៃបណ្តាឆ្នាំកន្លងមក ។ ចំណែកសោហ៊ុយធ្វើដំណើរ ស្នាក់នៅ បេសកកម្ម ត្រូវផ្អែកលើរបបកំណត់ជាធរមាន (អនុក្រឹត្យលេខ ១០ អនក្រ.ប្រក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុង និងក្រៅប្រទេស) ។

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំគម្រោងចំណាយថវិកាទៅតាមគំរូតារាងឧបសម្ព័ន្ធទី២ «ក» និង«ខ»ទន្ទឹមនោះត្រូវបំពេញតារាងលំអិតចំណាយតាមជំពូកនីមួយៗ (ចំនួន៧តារាង) ដែលភ្ជាប់ជាមួយនឹងសារាចរណែនាំនេះ ។

4. ចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយតាមជំពូក គណនី អនុគណនី ដើម្បីបង្ហាញឲ្យឃើញថា ការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវហ្មត់ចត់ និងសមហេតុផល។ លិខិតយុត្តិការទាំងអស់នេះនឹងធ្វើជាមូលដ្ឋាននៃការពិនិត្យពិភាក្សាថវិកា ។

### II.1. ការរៀបចំគម្រោងចំណាយចរន្ត

5. លិខិតយុត្តិការនៃចំណាយចរន្តមានគោលដៅសំខាន់ៗដូចតទៅ ៖

#### ប្រភេទ ១ : មធ្យោបាយសេវា
#### ជំពូក ៦២ និង ៦៤ សេវាខាងក្រៅផ្សេងៗ និងបន្ទុកបុគ្គលិក

6. ចំណាយសម្រាប់បុគ្គលិកត្រូវតែគិតគូរឲ្យបានច្បាស់លាស់ ។ ចំណាយលើជំពូក ៦៤ ត្រូវបានចាត់ទុកជាចំណាយដែលមានអាទិភាពបំផុតក្នុងការរៀបចំគម្រោងថវិកា ។ ចំណាយបន្ទុកបុគ្គលិកត្រូវគ្រោងដោយបង្កើន ២០% លើបៀវត្សមូលដ្ឋាននៃតារាងប្រាក់បៀវត្សដែលចេញដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្នុងឆ្នាំ ២០១១ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មីត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល

តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណៈភាពត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។

ចំពោះគម្រោងប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងនៅក្នុងជំពូក ៦៤ គណនី ៦៤៤ អនុគណនី ៦៤៤២ «លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខណ្ឌ » តាមការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ។

ក្នុងករណីដែលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតម្រូវការអំពីពលករអណ្តែត មន្ត្រីជាប់កិច្ចសន្យាសម្រាប់ការងារឯកទេសដែលត្រូវចុះកិច្ចសន្យាអនុវត្តសម្រាប់រយៈពេលខ្លីជាកំណត់ត្រូវគ្រោងនៅក្នុងជំពូក៦២ គណនី ៦២១ និងអនុគណនី ៦២១១ ។

7. ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមឱវាទរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបូកសរុបនៅក្នុងតារាង ៥«ក» និង ចំនួនក្រុមប្រឹក្សាទាំងអស់ត្រូវបូកសរុបនៅក្នុងតារាង ៥«ខ» ដែលបានភ្ជាប់ជូនមកជាមួយនេះ ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់ សម្រាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាន ។

8. បុគ្គលិក មន្ត្រីរាជការ ដែលលំអិតទៅតាមអង្គភាពនីមួយៗហើយ ចំនួននេះត្រូវតែផ្ទៀងផ្ទាត់ជាមួយនឹងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល)។

9. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវលម្អិតចំនួនបុគ្គលិកទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។

## ជំពូក ៦០ និង ៦១ ការទិញ និងសេវាខាងក្រៅ

10. ជំពូក ៦០ និង ៦១ ប្រមូលផ្តុំរាល់ការចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់រាជធានី ខេត្ត ។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ៖

មួយផ្នែកជាឥណទានសម្រាប់បំរើឲ្យកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរឲ្យបានហ្មត់ចត់ និងត្បិតត្បៀតសន្សំសំចៃដោយផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ ។ ក្នុងឆ្នាំ ២០១២ ឥណទានចំណាយផ្នែកនេះ គឺអនុញ្ញាតឲ្យគ្រោងក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០១១ តែប៉ុណ្ណោះ ។ ដោយឡែកថ្លៃឈ្នួល និងបន្ទុក (គណនី ៦១៣) គឺអនុញ្ញាតឲ្យគ្រោងតែចំណាយសម្រាប់ជួលស្នាក់ការរដ្ឋបាលតែប៉ុណ្ណោះ ។

មួយផ្នែកទៀតជាឥណទានសម្រាប់បំរើដល់គុណប្រយោជន៍របស់រាជធានី ខេត្តក្នុងការរៀបចំមូលដ្ឋានសម្ភារៈនៃសេវាសាធារណៈ និងការអភិវឌ្ឍរបស់រាជធានី ខេត្ត ។ ផ្អែកលើផែនការអភិវឌ្ឍរាជធានី ខេត្ត របស់ក្រសួងមហាផ្ទៃ រាជធានី ខេត្ត នីមួយៗចាំបាច់ត្រូវរៀបចំទៅតាមលំដាប់លំដោយនៃអាទិភាពរបស់គម្រោងចំណាយនីមួយៗ អំពីការងារជាគុណប្រយោជន៍របស់រាជធានី ខេត្ត ដើម្បីដាក់គម្រោងនេះឆ្លងការពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ក្នុងពេលធ្វើការពិភាក្សាគម្រោងថវិកាប្រចាំឆ្នាំ ។ ទន្ទឹមនោះ រាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់បង្កើននូវចំណាយផ្នែកនេះ ក្នុងករណីដែលលទ្ធភាពចំណូលសម្រេចបានលើសផែនការ ព្រោះការអភិវឌ្ឍរាជធានី ខេត្ត គឺជាគោលបំណងនៃគោលនយោបាយ និងជាទិសដៅយុទ្ធសាស្ត្រអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

11. អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវគ្រោងឥណទានសម្រាប់ចំណាយជាគុណប្រយោជន៍រាជធានី ខេត្ត តាមការងារនីមួយៗ (បំភ្លឺសាធារណៈ ប្រមូលសំរាម អនាម័យ សន្តិសុខ ប្រឆាំងអគ្គិភ័យ ការផ្គត់ផ្គង់ទឹក...) និងតាមការដ្ឋាននីមួយៗ (ផ្លូវថ្នល់ ស្ពាន សួនច្បារ លូទឹក ប្រឡាយ....) ដោយមានបញ្ជាក់អំពីបញ្ជីប៉ាន់តម្លៃ និងទីតាំងច្បាស់លាស់ដែលជាឯកសារសម្រាប់ការពិភាក្សាថវិកាប្រចាំឆ្នាំ ។

12. ជាទូទៅចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតម្រូវការនៃកម្មវិធីសកម្មភាពឬទៅតាមបទដ្ឋានសមស្រប ។ ម្យ៉ាងទៀតរាជធានី ខេត្ត មិនត្រូវបំប៉ោងឥណទានដែលស្នើសុំសម្រាប់ចំណាយប្រភេទនេះទេ ។ ឥណទានសម្រាប់ចំណាយអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ និងការទទួលភ្ញៀវ ត្រូវគិតគូរក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ ២០១១ និងត្រូវគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសម្រាប់ចំណាយអគ្គិសនី ទឹក រាជធានី ខេត្ត ត្រូវគ្រោងឲ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការក្នុងឆ្នាំ និងការសងបំណុល ។ ក្នុងករណីដែលរាជធានី ខេត្ត គ្រោងមិនបានគ្រប់គ្រាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូកថវិការបស់រាជធានី ខេត្ត ហើយដាក់កម្មវិធីចំណាយសម្រាប់ទូទាត់ជូនរាជធានី ខេត្ត ដោយស្វ័យប្រវត្តិ ។

## ប្រភេទ ៣ : ចំណាយអន្តរាគមន៍សាធារណៈ
## ជំពូក ៦៥ : ការឧបត្ថម្ភធន និងជំនួយសង្គម

13. ចំណាយប្រភេទនេះត្រូវថែងល់អិតឲ្យបានច្បាស់លាស់ នូវគោលដៅដែលត្រូវសម្រេច ។ ត្រូវពិនិត្យជ្រើសរើសចំណាយប្រភេទនេះឲ្យបានហ្មត់ចត់ ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផលនិងចំនួនទឹកប្រាក់ ដែលត្រូវពិនិត្យផ្តល់ជូន ។

## ប្រភេទ ៤ : ចំណាយផ្សេងៗ
## ជំពូក ៦៣ : ពន្ធ និងអាករ

14. ចំណាយប្រភេទនេះ គឺសម្រាប់កាតព្វកិច្ចពន្ធ ដូចចំណាយលើអាករ (លតាប័ត្រ....) ពន្ធប្រថាប់ត្រាសម្រាប់ទទួលកម្មសិទ្ធិ និងចំណាយបង់ពន្ធអាករផ្សេងៗទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រភេទ ៦ : ចំណាយមិនបានគ្រោងទុក
## ជំពូក ០៩ : ចំណាយមិនបានគ្រោងទុក

15. ចំណាយប្រភេទនេះ គឺជាការគិតគូរគ្រោងបំរុងសម្រាប់ចំណាយថែជន្យ ដែលអាចកើតមានជាយថាហេតុ នៅក្នុងឆ្នាំអនុវត្ត ។ សម្រាប់ឆ្នាំថវិកា ២០១២ ប្រភេទឥណទាននេះ គឺអនុញ្ញាតអោយគ្រោងចំនួន ៣ទៅ៥ភាគរយ ហើយខ្ទង់ចំណាយនេះពេលអនុវត្តត្រូវស្នើសុំធ្វើនិយ័តភាពទៅបំពេញឲ្យជំពូកដទៃទៀត ដែលតម្រូវការចំណាយថែជន្យកើតមានឡើងជាយថាហេតុ និងតម្រូវការចំណាយសម្រាប់អភិវឌ្ឍន៍រាជធានី ខេត្ត ។

## II.2. ចំណាយជាមូលធន :

### ប្រភេទ ២ : អចលកម្ម
### ជំពូក២០ និងជំពូក២១: អចលកម្មអរូបី និងអចលកម្មរូបី

16. ចំណាយជាមូលធន គឺជាចំណាយសម្រាប់ធ្វើហិរញ្ញប្បទានចំពោះគម្រោងវិនិយោគ ដែលមានការព្រមព្រៀងគ្នាជាមុន និងសំដៅធ្វើឲ្យសម្រេចតាមគោលដៅដែលបានដាក់ចេញ ។

17. គម្រោងវិនិយោគរបស់រាជធានី ខេត្ត ដែលអាចគ្រោងបានក្នុងករណីដែលរាជធានី ខេត្ត បានទទួលគោលការណ៍អនុញ្ញាតជាផ្លូវការឲ្យគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិការាជធានី ខេត្ត អាចគ្រោងបានក្នុងករណីដែលរាជធានី ខេត្ត មានអតិរេកចរន្ត ឬ មានចំណូលជាមូលធនផ្ទៃក្នុងរាជធានី ខេត្ត ផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ត្រូវផ្អែកលើកម្មវិធីជំនួយ ឬគម្រោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ឬ ម្ចាស់ជំនួយទ្វេភាគីបានទៅទំនាក់ទំនងផ្ទាល់ជាមួយរាជធានី ខេត្ត ដើម្បីកត់ត្រាចូលទៅក្នុងគម្រោងថវិការបស់រាជធានី ខេត្ត ។ ចំពោះហិរញ្ញប្បទានពីខាងក្រៅដែលបានធ្វើហិរញ្ញប្បទានទៅក្នុងមូលនិធិក្រុង ស្រុក ខេត្តសាមីត្រូវគ្រោង និងផ្តល់ព័ត៌មានដល់រដ្ឋបាលក្រុង ស្រុក ដើម្បីត្រៀមលក្ខណៈទទួលប្រតិភូកម្មក្នុងការអនុវត្ត ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀលដែលត្រូវអនុវត្តជាមួយគម្រោងដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ។

18. ចំណាយនេះជាចំណាយកសាងថ្មីដែលមានទំហំទឹកប្រាក់ច្រើន ដូចជា ការរៀបចំកែលំអដីធ្លី ការរៀបចំកែលំអអគារ សំណង់អគារហេដ្ឋារចនាសម្ព័ន្ធ បណ្តាញបង្ហូរទឹក ផ្លូវថ្នល់ ធារាសាស្ត្រ ស្ពាន និងសំណង់ផ្សេងៗទៀត ។

## III. សរុបគម្រោងចំណូល ចំណាយ :

19. ឆ្នាំ ២០១២ គឺជាឆ្នាំទី ៤ របស់រាជរដ្ឋាភិបាលអណត្តិទី ៤ រាជរដ្ឋាភិបាលបានព្យាករណ៍នូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់៦.៥ភាគរយ និងអត្រាអតិផរណាក្នុងរង្វង់៥ភាគរយ ហើយបន្តរក្សាបាននូវស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចនៅតែជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុតក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ការកាត់បន្ថយភាពក្រីក្រ ភាពសុខដុមរមនា និងសុភមង្គល របស់ប្រជាជន។

ផ្អែកលើមូលដ្ឋាននៃ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣** ពិសេស ដើម្បីបម្រើឲ្យការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយអភិវឌ្ឍតាមវិស័យ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០១២ មានគោលដៅសំខាន់ៗ ដូចតទៅ ៖

- ធានាឲ្យបាននូវការអនុវត្តគោលបំណង គោលនយោបាយ និងកម្មវិធីឬ/និងយុទ្ធសាស្ត្រអាទិភាពតាមវិស័យនៅក្នុងក្របខ័ណ្ឌនៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី** ២ តាមរយៈ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣** ។
- ធានាការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ជាពិសេស អាទរអភិវឌ្ឍវិស័យអាទិភាព រួមមានវិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍវិស័យឯកជន ដើម្បីរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ជំរុញកំណើន និងចីរភាពកំណើន។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំ រំកិល (២០១២-២០១៤)។

- ជានាបម្រើឲ្យការបន្តសកម្មភាពកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើគ្រប់ផ្នែក ដែលរួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ កំណែទម្រង់វិស័យកងទ័ព និងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ ដើម្បីពង្រឹងអភិបាលកិច្ចល្អ និងបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។
- ជានាបន្តផ្តល់អាទិភាពដល់បណ្តាវិស័យ ការដ្ឋាននិងសកម្មភាពការងារសំខាន់ៗ រួមមាន ៖
    - ការបង្កើន និងលើកកំពស់គុណភាពសេវាកម្មនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ សុខាភិបាល ការកសាងធនធានមនុស្ស និងសុវត្ថិភាពសង្គម ។
    - ការបង្កើន និងលើកកំពស់សកម្មភាពដែលបម្រើវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការអភិវឌ្ឍជនបទ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។
    - ការងារការពារអធិបតេយ្យភាព និងបូរណភាពទឹកដី ព្រមទាំងការបោះឆ្នោតព្រឹទ្ធសភា និងការបោះឆ្នោតឃុំ-សង្កាត់ ដើម្បីធានាប្រក្រតីភាពនៃដំណើរការប្រជាធិបតេយ្យការូបនីយកម្មថ្នាក់មូលដ្ឋាននៅកម្ពុជា ។

គម្រោងចំណូល ចំណាយថវិការបស់រាជធានី ខេត្ត នីមួយៗដែលបានគិតគូរ រួមមានទាំងការធានាចំណាយដែលមិនទាន់បានធ្វើការទូទាត់ និងចំណូលដែលមិនទាន់បានប្រមូលអស់នៃការគ្រប់គ្រងក្នុងឆ្នាំមុនៗ ។ គម្រោងចំណូល ចំណាយនេះត្រូវរៀបចំអោយមានគុណភាពពិតប្រាកដ ដើម្បីរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។

20. ចំពោះគម្រោងចំណូល ចំណាយរាជធានី ខេត្ត ត្រូវភ្ជាប់មកជាមួយនូវគម្រោងបែងចែកលំអិតតាមក្រុង ស្រុក ខណ្ឌនីមួយៗ ដូចដែលមានគំរូតារាងឧបសម្ពន្ធ២ « ខ » ដែលភ្ជាប់នឹងសារាចរណែនាំនេះ ។

21. ដោយឡែកនៅឆ្នាំ ២០១២ ខាងមុខនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសពង្រឹងនូវគោលដៅជំហានទី១ គឺភាពជឿទុកចិត្តបាននៃថវិកា តាមរយៈការបន្តជំរុញការកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបង្កើនភាពគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា ដើម្បីធានាឲ្យការបើកផ្តល់ថវិកាបានទាន់ពេលវេលា ។ ពង្រឹងការកសាងក្របខ័ណ្ឌគោលនយោបាយចំណូល ដើម្បីរក្សាស្ថេរភាពចំណូលប្រកបដោយនិរន្តរភាព និងការអនុវត្តគោលដៅជំហានទី២ ។ ទន្ទឹមនឹងនេះ បន្តជំរុញការរៀបចំផែនការសកម្មភាព និងបន្តអនុវត្តនូវបណ្តាលសកម្មភាពការងារសម្រាប់ឈានចូលនូវគោលដៅជំហានទី៣ និង ទី៤ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និងការពង្រឹងការឆ្លើយតបនៃថវិកាទៅនឹងគោលនយោបាយដែលរួមមាន ការបន្តពង្រឹង និងកែលំអការអនុវត្តប្លង់គណនេយ្យ និងមាតិកាថវិកាថ្មី ការបន្តពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី និងជំរុញការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បីរវាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្មីស្តែងឡើងជាសមិទ្ធិផល និងជាកំលាំងចលករក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

22. បន្តជំរុញអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពិសេសធានាពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សម្រាប់ការអភិវឌ្ឍមូលដ្ឋាន និងពង្រីកមូលដ្ឋាន នៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ ពិសេសគឺដើម្បីបំរើអោយគោលការណ៍ "រដ្ឋបាលឯកភាព" ដូចមានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងកម្មវិធីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំនិងអនុវត្តផែនការបង្កើនប្រសិទ្ធភាពនៃការផ្ទេរ និងការផ្តល់ថវិកាជូនមូលនិធិក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រួមមានទាំងលទ្ធភាពនៃការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងរៀបចំលិខិតបទដ្ឋាននានាដូចជា

អនុក្រឹត្យ សារាចរណែនាំសម្រាប់អនុវត្តប្រព័ន្ធហិរញ្ញវត្ថុ និងថវិការបស់រដ្ឋបាលនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីឲ្យការអនុវត្តមានប្រសិទ្ធភាពខ្ពស់ ។

23. បង្កើនមូលនិធិថវិកាឃុំ សង្កាត់ ឆ្នាំ ២០១២ ស្មើនឹង២,៨០% នៃចំណូលចរន្តថវិការដ្ឋឆ្នាំ ២០១១ ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ ។

24. ចំពោះការរៀបចំគម្រោងថវិកាថ្នាក់ ក្រុង ស្រុក ខណ្ឌ គណៈអភិបាលរាជធានី ខេត្ត ទទួលខុសត្រូវក្នុងការជួយគាំទ្របច្ចេកទេសដោយមានគម្រោងថវិការបស់ខ្លួនបានត្រឹមត្រូវ ។

អភិបាលនៃគណៈអភិបាលខេត្ត ត្រូវធ្វើការបូកសរុបគម្រោងថវិការបស់រាជធានី គម្រោងថវិការបស់ខេត្ត គម្រោងថវិការបស់ក្រុង គម្រោងថវិការបស់ស្រុក គម្រោងថវិការបស់ខណ្ឌ ក្នុងរាជធានី ខេត្តរបស់ខ្លួនចូលក្នុងទម្រង់ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់ជាមួយនូវគម្រោងថវិកា និងសេចក្តីអត្ថាធិប្បាយពន្យល់របស់ខេត្ត របស់ក្រុង របស់ស្រុក ហើយត្រូវផ្ញើគម្រោង និងឯកសារទាំងនេះមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

25. ពេលទទួលបានសារាចរណែនាំ រាជធានី ខេត្ត ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ទៅតាមតារាងឧបសម្ព័ន្ធតារាងគំរូ (ឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២ និងតារាងលេខ ១ ដល់លេខ ៧) ដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន) ចំនួនពីរច្បាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១១ ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិភាក្សាកម្រិតជំនាញ និងបូកសរុបសម្រាប់ពិភាក្សាចាប់ពីថ្ងៃទី ០១ ដល់ ៣១ ខែ សីហា ឆ្នាំ២០១១ ។ តួលេខគម្រោងចំណូល ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1.2.3) ហើយឯកត្តាទាបបំផុតគិតត្រឹម 0.1 លានរៀល ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ទាំងអស់នឹងខិតខំយកចិត្តទុកដាក់ចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- (ដើម្បីជូនជ្រាប)
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- (ដើម្បីមុខការ)
- ឯកសារ

រាជធានី ខេត្ត.....................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ការគ្រប់គ្រងឆ្នាំ ២០១២

ឧបសម្ព័ន្ធទី ១

## តារាងសរុបចំណូលថវិការបស់រាជធានី ខេត្ត

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | តារាងរាយមុខចំណូល (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០១១ | | | គម្រោងឆ្នាំ២០១២ |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | |
| | | | | | | | |

ថ្ងៃទី...........ខែ..................ឆ្នាំ ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី...........ខែ..................ឆ្នាំ ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ថ្ងៃទី...........ខែ..................ឆ្នាំ ២០១១

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

រាជធានី ខេត្ត.........................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ២«ក»

# ការគ្រប់គ្រងឆ្នាំ ២០១២

## តារាងសរុបចំណាយថវិការបស់រាជធានី ខេត្ត

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ការរាយមុខចំណាយ (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០១១ | | | គម្រោងឆ្នាំ ២០១២ | |
|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | រាជធានី ខេត្ត | ក្រុង ស្រុក..... |
| | | | | | | | | |

ថ្ងៃទី...........ខែ.................ឆ្នាំ ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី...........ខែ.................ឆ្នាំ ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ថ្ងៃទី...........ខែ.................ឆ្នាំ ២០១១

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

១៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី២ "ខ"

រាជធានី ខេត្ត............

# គម្រោងថវិកាឆ្នាំ ២០១២

## តារាងសរុបចំណាយថវិការបស់រាជធានី ខេត្ត............

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០១២ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុប | សាលាខេត្ត | សរុប ក្រុង ស្រុក ខណ្ឌ | ក្រុង..... | ស្រុក..... | ស្រុក..... | ស្រុក..... | ស្រុក..... | ស្រុក..... | ស្រុក..... | ស្រុក..... | ស្រុក..... |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

ថ្ងៃទី.............ខែ..............ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី.............ខែ..............ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី.............ខែ..............ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ............

# គម្រោងថវិកាឆ្នាំ ២០១២

## គម្រោងចំណាយលើការទិញ (ជំពូក ៦០)

តារាង ១

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

ថ្ងៃទី..............ខែ................ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី..............ខែ................ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី..............ខែ................ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

# គម្រោងថវិកាឆ្នាំ ២០១២ គម្រោងចំណាយលើសេវាខាងក្រៅ

## (ជំពូក ៦១)(គុណប្រយោជន៍រាជធានី ខេត្ត)

តារាង២

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

# គម្រោងថវិកាឆ្នាំ ២០១២

## គម្រោងចំណាយលើសេវាក្រៅផ្សេងៗ (ជំពូក ៦២)

តារាង ៣

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី......... ខែ ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

# គម្រោងថវិកាឆ្នាំ ២០១២

## គម្រោងចំណាយលើពន្ធ និង អាករ (ជំពូក ៦៣)

តារាង ៤

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**
**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**
**ហត្ថលេខា និង ត្រាអភិបាល**
**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

# គម្រោងថវិកាឆ្នាំ ២០១២

## គម្រោងចំណាយលើបន្ទុកបុគ្គលិក( ជំពូក ៦៤ )

តារាង ៥

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ ( តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី..............ខែ...............ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តារាង៥ "ក"

រាជធានី ខេត្ត...............

# ការគ្រប់គ្រងឆ្នាំ ២០១២

## តារាងសរុបនៃបុគ្គលិក បៀវត្ស និងប្រាក់បំណាច់

| អង្គភាព | បៀវត្ស | ចំនួនបុគ្គលិក | ប្រភេទបុគ្គលិកដែលមានសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ | | | | | ពលករ | មន្ត្រី |
|---|---|---|---|---|---|---|---|---|---|
| | សរុប | សរុប | បុគ្គ.អចិន្ត្រៃយ៍សរុប | ប្រភេទ«ក» | ប្រភេទ«ខ» | ប្រភេទ«គ» | ប្រភេទ«ឃ» | អណ្តែត | ជាប់កិច្ចសន្យា |
| សរុប | | | | | | | | | |
| សាលាខេត្ត | | | | | | | | | |
| ក្រុង | | | | | | | | | |
| ស្រុក ឬ ខណ្ឌ | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| ............................ | | | | | | | | | |
| ........................... | | | | | | | | | |
| ............................. | | | | | | | | | |

ថ្ងៃទី............ខែ..................ឆ្នាំ ២០១១

ថ្ងៃទី...............ខែ................ឆ្នាំ ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ថ្ងៃទី............ខែ..................ឆ្នាំ ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អ្នកធ្វើតារាង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត...............

តារាង៥-ខ-

## ការគ្រប់គ្រងឆ្នាំ ២០១២

## តារាងសរុបនៃបុគ្គលិក បៀវត្ស និងប្រាក់បំណាច់

| អង្គភាព | សរុប: | ប្រភេទក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ចំនួនប្រធានក្រុមប្រឹក្សា | | ទឹកប្រាក់ | ចំនួនសមាជិកក្រុមប្រឹក្សា | | ទឹកប្រាក់ | ផ្សេងៗ |
| សាលារាជធានី ខេត្ត | | | | | | | | |
| ក្រុង | | | | | | | | |
| ស្រុក-ខណ្ឌ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបរួម: | | | | | | | | |

ថ្ងៃទី............... ខែ................ ឆ្នាំ ២០១១

ថ្ងៃទី............... ខែ................ ឆ្នាំ ២០១១

ថ្ងៃទី............... ខែ................ ឆ្នាំ ២០១១

**បានឃើញ និង ឯកភាព**
**ហត្ថលេខា និង ត្រាអភិបាល**
**នៃគណៈអភិបាលរាជធានី ខេត្ត**

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**
**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អ្នកធ្វើតារាង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត............**

# គម្រោងថវិកាឆ្នាំ ២០១២

## គម្រោងចំណាយលើឧបត្ថម្ភកធន និងជំនួយសង្គម (ជំពូក ៦៥)

តារាង ៦

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

ថ្ងៃទី.............ខែ...............ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី.............ខែ...............ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី.............ខែ...............ឆ្នាំ ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

# គម្រោងថវិកាឆ្នាំ ២០១២

## អចលកម្មអរូបីយ៍ និងអចលកម្មរូបីយ៍ (ជំពូក ២០ និង ២១)

តារាង ៧

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

ថ្ងៃទី............ខែ..............ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី............ខែ..............ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី............ខែ..............ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**